## ផែនការយុទ្ធសាស្ត្រឆ្នាំ ២០២០ - ២០២៤ របស់សាលាអន្តរជាតិភ្នំពេញ

### សេចក្តីផ្តើម

យើងខ្ញុំមានក្តីរីករាយសូមបង្ហាញជូនផែនការយុទ្ធសាស្ត្រឆ្នាំ ២០២០-២០២៤ របស់សាលាអន្តរជាតិភ្នំពេញ។ ផែនការនេះចងក្រង និងស្ថាបនាបន្ថែមលើសមិទ្ធផលគួរជាទីកត់សម្គាល់នានារបស់សាលាអន្តរជាតិភ្នំពេញក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ នៅក្នុងអំឡុងពេលដែលផែនការកន្លងមកត្រូវបានបង្កើតឡើង សាលានៅកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល ដោយត្រូវផ្លាស់មកកាន់មណ្ឌលសាលារៀនថ្មី។ បច្ចុប្បន្នដំណើរការផ្លាស់ប្តូរទីតាំងនោះបានបញ្ចប់សព្វគ្រប់ហើយ ហើយបរិក្ខារទាំងអស់ត្រូវបានស្ថាបនា និងបំពេញមុខងារបានពេញលេញល្អ យើងអាចសម្លឹងឆ្ពោះទៅអនាគត និងមើលឃើញថាតើធ្វើយ៉ាងណាដើម្បីអាចស្ថាបនាបន្ថែមលើចំណុចខ្លាំង និងជោគជ័យរបស់សាលាអន្តរជាតិភ្នំពេញឆ្ពោះទៅអនាគតទៀត។ ក្នុងកិច្ចការនេះ យើងចាំបាច់ត្រូវព្យាយាមឱ្យមានមហិច្ឆតាខ្ពស់ទាក់ទងជាមួយ៖ ការពង្រឹងគុណភាព និងទំហំឱកាសការអប់រំដែលអាចផ្តល់ជូនសិស្សានុសិស្សរបស់យើង ពង្រីកការទំនាក់ទំនងផ្សព្វផ្សាយរបស់យើងទៅគ្រប់សញ្ជាតិ និងក្រុមទាំងអស់ក្នុងសហគមន៍របស់សាលាអន្តរជាតិភ្នំពេញ និងបន្តការប្តេជ្ញាចិត្តនាពេលបច្ចុប្បន្នរបស់យើង ចំពោះបរិស្ថាន និងសុខុមាលភាពបន្តទៀត។ តាមរយៈការអនុវត្តផែនការនេះ យើងរំពឹងថាសាលាអន្តរជាតិភ្នំពេញនឹងរក្សា ព្រមទាំងបន្តឋានៈរបស់ខ្លួនក្នុងនាមជាសាលាអន្តរជាតិនាំមុខគេក្នុងប្រទេសកម្ពុជា ដែលផ្តល់ការអប់រំកម្រិតពិភពលោក ជូនដល់សិស្សរបស់ខ្លួន។

នៅក្នុងទំព័រខាងក្រោយនេះ អ្នកនឹងឃើញគោលដៅ គោលបំណង និងសកម្មភាពជាសក្តានុពល ប្រកបដោយក្តីប្រាថ្នាខ្ពស់ សម្រាប់សសរស្តម្ភចម្បងទាំងបួន របស់ផែនការរបស់យើងគឺ ការរៀនសូត្រ សហគមន៍ បរិស្ថាន និងសុខុមាលភាព។ ក្រោយពីបានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល ក្របខណ្ឌការងារយុទ្ធសាស្ត្រនេះ នឹងត្រូវយកទៅអភិវឌ្ឍបន្ថែមទៀត ក្នុងវិធីចំនួន ៣ ៖

- កូនសៀវភៅព័ត៌មាន ដែលអធិប្បាយអំពីទិដ្ឋភាពទូទៅរបស់ផែនការក្នុងការប្រាស្រ័យទាក់ទងទៅកាន់សហគមន៍សាលាអន្តរជាតិភ្នំពេញ និងអ្នកពាក់ព័ន្ធដទៃទៀត

– ផែនការលម្អិត ព្រមជាមួយក្របខណ្ឌការងារលទ្ធផល សម្រាប់ក្រុមប្រឹក្សាភិបាល និងរដ្ឋបាលសាលា ដើម្បីតាមដានវឌ្ឍនភាព និង
– ឯកសារស្តីពីការធ្វើផែនការប្រតិបត្តិការ ដើម្បីជាមគ្គុទេសក៍សម្រាប់បុគ្គលិកសិក្សា និងបុគ្គលិកទាំងអស់ក្នុងការអនុវត្ត

យើងក៏កំពុងបង្កើតគោលដៅ និងគោលបំណងសម្រាប់អភិបាលកិច្ច និងការគាំទ្រផ្នែកប្រតិបត្តិការ ដែលចាំបាច់ដើម្បីអនុវត្តសសរស្តម្ភចម្បង របស់ផែនការនេះផងដែរ។

សូមខ្ញុំសូមស្ញើចសរសើរ និងអរគុណចំពោះកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់អ្នកទាំងអស់គ្នា ដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍផែនការនេះ តាមរយៈការចូលរួមរបស់ពួកគាត់នៅក្នុងគណៈកម្មាធិការនានា។

- *រដ្ឋបាលសាលារៀន៖* Lindy Leonardt, Michael Hodgson
- *ក្រុមប្រឹក្សាភិបាល៖* John Collins, Mimi Concha, Anne-Sarine Courcoux, Peter Herum, John Hustedt, Keng Somarith, Jennifer Morellato, Mot Song Heng, Ponlu Tola, Clarisse Kehler Siebert (ទីប្រឹក្សា), Edwin van Olst
- *បុគ្គលិកសិក្សា៖* Elizabeth Ford, Rachel Garthe, Angelique Hiscox, Lynn Hommeyer, Mary-Anne Muhl, Tom Parun, Sandy Pascolini, Murray Polglase, Jonathan Smedes, Adriana Vargas
- *បុគ្គលិកប្រតិបត្តិការ៖* Chea Bunthida, Keo Manin, Neb Trajkovic
- *ឪពុកម្តាយ៖* Lendell Foan, Scott Johnson, Narendra Kumar, George Taylor, Holger Theis

ទិដ្ឋភាពទូទៅនៃដំណើរការ ដែលត្រូវបានអនុវត្តដើម្បីបង្កើតផែនការនេះ គឺមានបញ្ជាក់ខាងក្រោម។

| | |
|---|---|
| Gareth Jones | Jenny Pearson |
| នាយកសាលា | សមាជិកក្រុមប្រឹក្សាភិបាល<br>ប្រធានគណៈកម្មាធិការផែនការយុទ្ធសាស្ត្រ |

**ទិដ្ឋភាពទូទៅនៃដំណើរការធ្វើផែនការ**

ក្នុងអំឡុងឆ្នាំសិក្សា ២០១៨/២០១៩ គណៈកម្មាធិការផែនការយុទ្ធសាស្ត្រ (SPC) ត្រូវបានបង្កើតឡើង និងអនុវត្តជំហានបែបការចូលរួមជាច្រើន។ ជំហានទាំងអស់នោះរួមមានដូចជា ការចាត់បេសកកម្មះ ការសិក្សាកំណត់

ស្តង់ដារដើម្បីវាយតម្លៃថាតើសាលាអន្តរជាតិភ្នំពេញស្ថិតនៅទីណាបើធៀបជាមួយសាលាអន្តរជាតិដទៃទៀតក្នុងប្រទេសកម្ពុជា, ការសិក្សាផ្ទៃក្នុង និងរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ននៃការគាំទ្រការរៀនសូត្រប្រកបដោយបរិយាបន្ន ដោយមានអនុសាសន៍អំពីរបៀបដើម្បីឈានឆ្ពោះទៅមុខ, ការសិក្សាអង្កេតអំពីសិស្ស គ្រួសារ បុគ្គលិកសិក្សា និងបុគ្គលិកទាំងអស់អំពីសេចក្តីថ្លែងមគ្គុទ្ទេសក៍របស់សាលា, និងការវាយតម្លៃសមិទ្ធផលធៀបជាមួយផែនការយុទ្ធសាស្រ្តបច្ចុប្បន្ន។

នៅដើមឆ្នាំសិក្សានេះ អនុគណៈកម្មាធិការចំនួន ៦ ត្រូវបានបង្កើតឡើង ដើម្បីធ្វើការលើទិដ្ឋភាពផ្សេងៗរបស់ផែនការ ដោយក្នុងនោះអនុគណៈកម្មាធិការចំនួន ៣ ធ្វើការលើសសរស្តម្ភចម្បង ហើយអនុគណៈកម្មាធិការចំនួន ៣ ទៀតធ្វើការភាគច្រើនលើការគាំទ្រដល់អភិបាលកិច្ច និងបញ្ហាផ្នែកប្រតិបត្តិការ។ អនុគណៈកម្មាធិការត្រូវបានបង្កើតឡើង ដោយមានអ្នកតំណាងមកពីបុគ្គលិកសិក្សា បុគ្គលិក និងឪពុកម្តាយ។

ដំណើរការនៃការធ្វើផែនការចម្បង បានចាប់ផ្តើមនៅក្នុងអំឡុងពេលប្រជុំបូកសរុបរបស់ក្រុមប្រឹក្សាភិបាល ក្នុងខែកញ្ញា នៅពេលដែលក្រុមប្រឹក្សាភិបាល និង SPC បានធ្វើការរួមគ្នាដើម្បីវិភាគសព្វជ្រុងជ្រោយទៅលើចំណុចខ្លាំង ចំនុចខ្សោយ ឱកាស ការគំរាម ក្តីប្រាថ្នា និងលទ្ធផល។ បន្ទាប់មក ធាតុចេញទាំងអស់នេះ ត្រូវបានយកទៅដាក់ក្នុងការងាររបស់អនុគណៈកម្មាធិការ ដែលមានភារកិច្ចដើម្បី៖

- វិភាគបរិបទយុទ្ធសាស្រ្ត ដោយប្រើប្រាស់ពហុប្រភពទិន្នន័យ ដូចជារបាយការណ៍ទទួលស្គាល់គុណភាព លទ្ធផលការសិក្សាអង្កេត ការស្រាវជ្រាវពីអ៊ីនធឺណិតស្តីពីនិន្នាការនៃការគិតនាពេលបច្ចុប្បន្នលើការអនុវត្តប្រសើរបំផុត។ល។
- ការវិភាគជាយុទ្ធសាស្រ្តលើស្ថានភាពបច្ចុប្បន្នរបស់សាលា ទាក់ទងជាមួយចំណុចខ្លាំង ចំនុចខ្សោយ ឱកាស និងការគំរាម។ ឆ្លងតាមរយៈការវិភាគនេះ គណៈកម្មាធិការនីមួយៗ មានលទ្ធភាពអាចកំណត់រកប្រធានបទជាយុទ្ធសាស្រ្ត និងបញ្ហានានាសម្រាប់យកមកពិចារណា ដែលបានជួយសម្របសម្រួល ក្នុងការកំណត់ថា តើអ្វីខ្លះដែលយើងគួរ "ឈប់ធ្វើ" "បន្តធ្វើ" និង "ចាប់ផ្តើមធ្វើ"។
- ផ្តល់អនុសាសន៍សម្រាប់គោលដៅជាក្តីប្រាថ្នា និងគោលបំណងជាយុទ្ធសាស្រ្តសម្រាប់សសរស្តម្ភនីមួយៗ ព្រមជាមួយសកម្មភាពជាសក្តានុពលកម្រិតខ្ពស់ដែលត្រូវធ្វើឡើង

អនុសាសន៍បានមកពីគណៈកម្មាធិការនីមួយៗ ត្រូវបាននាំយកមកដាក់រួមគ្នា រួចពិនិត្យឡើងវិញដោយក្រុមប្រឹក្សាភិបាល និង SPC ជាលទ្ធផលធ្វើឱ្យកើតមានក្របខ័ណ្ឌការងារយុទ្ធសាស្រ្តដូចមានបង្ហាញជូនក្នុងឯកសារនេះ។

## សសរស្តម្ភចម្បងនៃផែនការយុទ្ធសាស្រ្តឆ្នាំ ២០២០-២០២៤ របស់សាលាអន្តរជាតិភ្នំពេញ

ការរៀនសូត្រ សហគមន៍ បរិស្ថាន និងសុខុមាលភាព

### ១. សសរស្តម្ភការរៀនសូត្រ

**គោលដៅជាទីប្រាថ្នា៖**

**នៅសាលាអន្តរជាតិភ្នំពេញ យើងបង្កឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីក្រុមអ្នករៀនសូត្រចម្រុះគ្នា តាមរយៈកម្មវិធីមានលក្ខណៈសព្វជ្រុងជ្រោយ ក្នុងការបង្រៀនដ៏ល្អបំផុត និងការប្រតិបត្តិការរៀនសូត្រដោយមានការគាំទ្រពីការប្រើប្រាស់បច្ចេកវិទ្យាសមស្រប។**

**គោលបំណងយុទ្ធសាស្រ្ត ១.១**

សាលាអន្តរជាតិភ្នំពេញមានសមត្ថភាពពាក់ព័ន្ធជាមួយកម្មវិធី ធនធាន រចនាសម្ព័ន្ធ និងបុគ្គលិក ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់សិស្សដែលមានលក្ខណៈចម្រុះគ្នារបស់ខ្លួន ពង្រឹងបរិយាបន្នសម្រាប់សិស្សដែលមានសេចក្តីត្រូវការផ្សេងៗគ្នា។

**តើយើងអាចដឹងដោយរបៀបណា?**

- ភស្តុតាងដែលបង្ហាញអំពីចំនួនសិស្សមានលទ្ធភាពចូលទៅកាន់គន្លងការអប់រំនានានៅសាលាអន្តរជាតិភ្នំពេញ ដែលផ្តល់ឱកាសសម្រាប់សិស្សផ្សេងៗគ្នា អាចមានវឌ្ឍនភាពឈានឆ្ពោះទៅមុខ និងទទួលបាន IBDP, ISPP ឌីប្លូម៉ា ឬ ISPP ឌីប្លូម៉ាកែសម្រួល
- មានដំណើរការគាំទ្រការផ្លាស់ប្រែប្រកបដោយប្រសិទ្ធភាព ហើយត្រូវបានពិនិត្យតាមដានសម្រាប់សិស្សដែលចូលមក និងចេញពីសាលា និងអ្នកដែលត្រូវស្ថិតក្នុងដំណាក់កាលឆ្លងកាត់ផ្ទៃក្នុង
- ភស្តុតាងដើម្បីបង្ហាញថា មានសេវាគាំទ្រ ហើយសេវាទាំងនោះត្រូវបានទទួលយក ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការផ្សេងៗគ្នារបស់សិស្សទាំងអស់

**សកម្មភាពជាសក្តានុពល ១.១.i**

- ពិនិត្យឡើងវិញលើគន្លងការអប់រំបច្ចុប្បន្ន ហើយប្រសិនបើចាំបាច់ ត្រូវបង្កើតគន្លងការអប់រំបន្ថែម និងជម្រើសសម្រាប់សិស្ស ដើម្បីឆ្លងពីគន្លងមួយទៅគន្លងមួយទៀត យោងតាមសេចក្តីត្រូវការរបស់ពួកគេ។

**សកម្មភាពជាសក្តានុពល ១.១.ii**

- ធានាឱ្យមានការផ្តល់កម្មវិធីភាសានៅសាលារៀនទាំងមូលជាបន្តបន្ទាប់ សម្រាប់ភាសានៃការបង្រៀនជាទូទៅ ការទទួលបានបំណិនភាសាទីមួយ និងភាសាបរទេស។

**សកម្មភាពជាសក្តានុពល ១.១.iii**

- ស្ថាបនា និងរក្សាគោលវិធីរួម ដើម្បីផ្តល់សេវាគាំទ្រក្នុងសាលារៀនទាំងមូល។

**សកម្មភាពជាសក្តានុពល ១.១.iv**

- ពង្រីកឱកាសសិក្សារៀនសូត្រឱ្យបានទូលំទូលាយ សម្រាប់ឪពុកម្តាយ ដើម្បីជួយពួកគាត់ឱ្យអាចគាំទ្រការសិក្សារៀនសូត្ររបស់កូន និងពិនិត្យតាមដានលើជម្រើសនានា ដើម្បីកំណត់ថាតើជម្រើសណាខ្លះដែលមានប្រសិទ្ធភាពបំផុត។

**សកម្មភាពជាសក្តានុពល ១.១.v**

- ពិនិត្យឡើងវិញ និងអភិវឌ្ឍដំណើរការគាំទ្រ ការផ្លាស់ប្រែសម្រាប់សិស្សដែលចូលមក និងចាកចេញពីសាលាអន្តរជាតិភ្នំពេញ និងអ្នកដែលត្រូវស្ថិតក្នុងដំណាក់កាលឆ្លងកាត់ផ្ទៃក្នុង

**គោលបំណងយុទ្ធសាស្ត្រ ១.២**

សិស្សទទួលបទពិសោធន៍ការអប់រំមានមូលដ្ឋានទូលំទូលាយ ដែលត្រូវបានពង្រឹងដោយសកម្មភាពក្រៅកម្មវិធីសិក្សា និងការទទួលយកឱកាសនានា ដែលផ្តល់ជម្រើសសម្រាប់ការសិក្សារៀនសូត្រជាជម្រើសជំនួស។

**តើយើងអាចដឹងដោយរបៀបណា?**

- ទំហំឱកាស និងកម្រិតនៃការទទួលយកសកម្មភាពក្រៅកម្មវិធីសិក្សា (ASP)
- ទំហំឱកាស និងកម្រិតនៃការទទួលយកវិស័យកីឡា សិល្បៈ STEM, MUN ។ល។
- ទំហំឱកាស និងកម្រិតនៃការទទួលយកកិច្ចខិតខំទាក់ទងជាមួយភាពជាពលរដ្ឋសកលសហគ្រិនភាព និងការអប់រំវិជ្ជាជីវៈ
- បរិក្ខារអប់រំក្រៅបន្ទប់សិក្សាត្រូវបានអភិវឌ្ឍ ហើយយកមកអនុវត្ត ដើម្បីពង្រឹងឱកាសអប់រំ សម្រាប់សហគមន៍សាលាអន្តរជាតិភ្នំពេញទាំងមូល

**សកម្មភាពជាសក្តានុពល ១.២.i**

- បន្ត ពិនិត្យឡើងវិញ និងធ្វើពិពិធកម្ម ASP។

**សកម្មភាពជាសក្តានុពល ១.២.ii**

- បន្តការចូលរួមក្នុង MRISA, ISAPP, MUN, ISTA, ArtsX, និងសកម្មភាពពាក់ព័ន្ធដទៃទៀត។

**សកម្មភាពជាសក្តានុពល ១.២.iii**

- ពិនិត្យតាមដានទំហំ និងគុណភាពនៃការផ្តល់សកម្មភាពក្រៅកម្មវិធីសិក្សា ដើម្បីធានាឱ្យមានតុល្យភាព

**សកម្មភាពជាសក្តានុពល ១.២.iv**

- អភិវឌ្ឍផែនការដើម្បីប្រើប្រាស់មជ្ឈមណ្ឌលអប់រំក្រៅបន្ទប់រៀន និងធានាថា ផែនការទាំងនោះត្រូវបានស្ថាបនាឡើងសម្រាប់គោលបំណងជាក់លាក់ ហើយត្រូវបានប្រើប្រាស់យ៉ាងពេញលេញ ដើម្បីសម្រេចបានគោលបំណងនៃការសិក្សារៀនសូត្រពាក់ព័ន្ធ។

**គោលបំណងយុទ្ធសាស្ត្រ ១.៣**

បច្ចេកវិទ្យាត្រូវបានលើកកម្ពស់ប្រកបដោយការទទួលខុសត្រូវ ដើម្បីពង្រឹង ពិនិត្យតាមដាន និងរាយការណ៍អំពីសមិទ្ធផលការសិក្សារៀនសូត្រ។

**តើយើងអាចដឹងដោយរបៀបណា?**

- យោបល់ត្រឡប់ជាវិជ្ជមានពីការសិក្សាអង្កេត CIS (លើស ៩០ ភាគរយ = ការអបអរ)
- សូចនាករដែលពិនិត្យតាមដានទិដ្ឋភាពទាំងអស់នៃការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយការទទួលខុសត្រូវ ដែលត្រូវបានបង្កើតឡើងនៅក្នុងផែនការបច្ចេកវិទ្យាអប់រំ (ETP)

**សកម្មភាពជាសក្តានុពល ១.៣.i**

- អភិវឌ្ឍ និងប្រើប្រាស់ ETP យ៉ាងឯកភាពគ្នា ដោយរួមមានសូចនាករសម្រាប់ការប្រើប្រាស់ប្រកបដោយភាពទទួលខុសត្រូវ។

**សកម្មភាពជាសក្តានុពល ១.៣.ii**

- ការអភិវឌ្ឍ និងការតម្លើងកម្រិតបច្ចេកវិទ្យាជាបន្តបន្ទាប់ សម្រាប់ការសិក្សារៀនសូត្ររបស់សិស្សអនុលោមតាម ETP ។

**សកម្មភាពជាសក្តានុពល ១.៣.iii**

- ផ្តល់ឱកាសដល់បុគ្គលិកសិក្សា និងផ្នែករដ្ឋបាលសាលា ដើម្បីសិក្សាស្វែងយល់ និងចែករំលែកបច្ចេកវិទ្យាផ្សេងៗ ដែលនឹងជួយពង្រឹងវិធីសាស្ត្រនៃការរៀនសូត្រ និងការគ្រប់គ្រង។

**គោលបំណងយុទ្ធសាស្ត្រ ១.៤**

សាលាអន្តរជាតិភ្នំពេញគឺជាមជ្ឈមណ្ឌលនៃការរៀនសូត្រប្រកបដោយវិជ្ជាជីវៈនៅក្នុងតំបន់។

**តើយើងអាចដឹងដោយរបៀបណា?**

- ធ្វើជាម្ចាស់ផ្ទះសម្រាប់ IB និងសិក្ខាសាលាថ្នាក់តំបន់ដទៃទៀត
- ធ្វើជាម្ចាស់ផ្ទះសម្រាប់បណ្តាញមិត្តជួយមិត្ត
- បង្កើនលទ្ធភាពគ្រូរបស់សាលាអន្តរជាតិភ្នំពេញឱ្យមានលទ្ធភាពទទួលបានការអភិវឌ្ឍវិជ្ជាជីវៈនៅក្នុងស្រុក

**សកម្មភាពជាសក្តានុពល ១.៤.i**

- កំណត់រក និងដាក់ឱ្យមានធនធានដែលចាំបាច់ រួមទាំងការអភិវឌ្ឍទំនាក់ទំនងជាមួយវិទ្យាស្ថាន ទីភ្នាក់ងារ និងអ្នកជំនាញពាក់ព័ន្ធនៅក្នុងវិស័យអប់រំអន្តរជាតិទូលំទូលាយ។

**សកម្មភាពជាសក្តានុពល ១.៤.ii**

- ផ្តល់ឱ្យមាន និងបន្តអភិវឌ្ឍកម្មវិធី ដើម្បីឱ្យមានការចូលរួមពីគ្រូកម្ពុជានៅក្នុងវិស័យអប់រំថ្នាក់ជាតិ។

## ២. សសរស្តម្ភសហគមន៍

**គោលដៅជាទីប្រាថ្នា៖**
**សាលាអន្តរជាតិភ្នំពេញក្លាយជាមជ្ឈមណ្ឌលដែលផ្តលភាពសម្បូរបែបដល់សហគមន៍តាមរយៈការអប់រំ សកម្មភាពសប្បុរស សិល្បៈ កីឡា និងវប្បធម៌។**

**គោលបំណងយុទ្ធសាស្ត្រ ២.១**
សហគមន៍សាលាអន្តរជាតិភ្នំពេញ ត្រូវបានពង្រឹងតាមរយៈសកម្មភាពនៅក្នុងមណ្ឌលសាលាទាំងមូល ព្រឹត្តិការណ៍ បទពិសោធន៍ការសិក្សារៀនសូត្រ និងឱកាសផ្សេងៗទៀតជាច្រើន ដើម្បីឱ្យមានភាពសម្បូរបែបសម្រាប់ស្ថាប័នសិស្ស បុគ្គលិកសិក្សា និងបុគ្គលិកដទៃ រួមទាំងសហគមន៍សាលាអន្តរជាតិភ្នំពេញទាំងមូល។

**តើយើងអាចដឹងដោយរបៀបណា?**

- លទ្ធផលការសិក្សាអង្កេតលើកម្រិតនៃការពេញចិត្ត
- មនុស្សកាន់តែច្រើននៅក្នុងមណ្ឌលសាលារៀន បានចូលរួមនៅក្នុងសកម្មភាពរួមកាន់តែច្រើន

| |
|---|
| **សកម្មភាពជាសក្តានុពល ២.១.i**<br>- បង្កើត និងអនុវត្តផែនការមានកញ្ចប់ថវិកា សម្រាប់ការពង្រីកជាដំណាក់កាលៗ និងការផ្តល់ធនធាន សម្រាប់សកម្មភាពមិននៅក្នុងកម្មវិធីសិក្សា និងលទ្ធភាពរបស់សហគមន៍ ក្នុងការចូលមកកាន់មណ្ឌលសាលារៀន និងបរិក្ខារនានា (រួមទាំងមជ្ឈមណ្ឌលនៅក្រៅបន្ទប់រៀន)។ |
| **សកម្មភាពជាសក្តានុពល ២.១.ii**<br>- ធានាឱ្យមានចំណងតភ្ជាប់សមស្រប ជាមួយការផ្តួចផ្តើមគំនិតនានា ក្នុងសសរស្តម្ភការរៀនសូត្រ ដើម្បីអភិវឌ្ឍឱកាសការអប់រំបែបសព្វជ្រុងជ្រោយ របស់សាលាអន្តរជាតិភ្នំពេញសម្រាប់ទាំងអស់គ្នា។ |
| **គោលបំណងយុទ្ធសាស្រ្ត ២.២**<br>ដើម្បីឱ្យមានកម្មវិធីសប្បុរសធម៌ បែបចម្រុះ ដែលគ្របដណ្តប់លើកម្មវិធីអាហារូបករណ៍ ភាពជាពលរដ្ឋសកល និងកម្មវិធីការអប់រំផ្សព្វផ្សាយក្នុងនាមជាប្រទេសម្ចាស់ផ្ទះ។<br><br>**តើយើងអាចដឹងដោយរបៀបណា?**<br>- មានគោលនយោបាយច្បាស់លាស់ដើម្បីដាក់បញ្ចូលកិច្ចការសប្បុរសធម៌នៅក្នុងវប្បធម៌សាលារៀន ហើយក្រុមទាំងអស់នៅក្នុងសហគមន៍ដឹង និងយល់អំពីគុណតម្លៃរបស់គោលនយោបាយនេះ |
| **សកម្មភាពជាសក្តានុពល ២.២.i**<br>- អភិវឌ្ឍ និងអនុវត្តគោលនយោបាយសប្បុរសធម៌ ដែលមានចែងអំពីគុណតម្លៃ ធាតុផ្សំ និងសកម្មភាពរបស់កម្មវិធី។ |
| **គោលបំណងយុទ្ធសាស្រ្ត ២.៣**<br>PCO ដែលមានអ្នកតំណាងតាមសញ្ជាតិ និងក្នុងកិច្ចសហការជាមួយសាលាអន្តរជាតិភ្នំពេញ ជាអ្នកកាច់ចង្កូតការផ្តួចផ្តើមគំនិត ដើម្បីគាំទ្រដល់សាលារៀន និងបង្កឱ្យមានការចូលរួមពីគ្រប់ក្រុមសញ្ជាតិទាំងអស់។<br><br>**តើយើងអាចដឹងដោយរបៀបណា?**<br>- ចំនួនក្រុមតាមសញ្ជាតិផ្សេងៗ មានការចូលរួមនៅក្នុងសកម្មភាពរបស់សាលាគ្រប់ប្រភេទទាំងអស់<br>- លទ្ធផលការសិក្សាអង្កេតឆ្លុះបញ្ចាំងឱ្យឃើញថា ការចូលរួមមានការកើនឡើង ពីក្រុមសញ្ជាតិកាន់តែច្រើន និងមានការពេញចិត្តកាន់តែច្រើន ចំពោះការចូលរួមជាមួយសាលា |
| **សកម្មភាពជាសក្តានុពល ២.៣.i**<br>- បង្កើត PCO ឡើងវិញ ដើម្បីធានាឱ្យបានថា មានអ្នកតំណាងតាមសញ្ជាតិ និងតាមកម្រិតថ្នាក់ ដោយមានអាណត្តិត្រូវបានកែសម្រួលឡើងវិញ ដើម្បីគាំទ្រដល់សិស្ស និងគ្រួសារឱ្យធ្វើការផ្លាស់ប្រែ |

និងរៀបចំ និង/ឬគាំទ្រដល់សកម្មភាពទូទាំងសាលា។

**សកម្មភាពជាសក្ដានុពល ២.៣.ii**

- ស្រាវជ្រាវរកយុទ្ធសាស្ត្រប្រកបដោយជោគជ័យ ដែលសាលាអន្តរជាតិដទៃទៀតធ្លាប់បានយកមកប្រើប្រាស់។

## ៣. <u>សសរស្តម្ភបរិស្ថាន</u>

**គោលដៅជាទីប្រាថ្នា**

**សាលាអន្តរជាតិភ្នំពេញ រក្សា និងបន្តការផ្តួចផ្តើមគំនិតដែលមានបច្ចុប្បន្នឱ្យមាននិរន្តភាព ដើម្បីឱ្យមានផលប៉ះពាល់ជាវិជ្ជមាន លើជានជើងបរិស្ថានរបស់ខ្លួន អភិវឌ្ឍឱកាសថ្មីៗ និងអាចបង្ហាញឱ្យឃើញអំពីផលប៉ះពាល់នៅកម្រិតសាលារៀន សហគមន៍ តំបន់ និងសាកល។**

**គោលបំណងយុទ្ធសាស្ត្រ ៣.១**

ដាក់ឱ្យមានយុទ្ធសាស្ត្រទូទាំងសាលារៀន ដោយមានគោលដៅសមស្របដើម្បីសម្របសម្រួល និងបានបន្សីជាមួយការផ្តួចផ្តើមគំនិតផ្នែកបរិស្ថាននាពេលបច្ចុប្បន្ន និងអនាគតទាំងអស់។

**តើយើងអាចដឹងដោយរបៀបណា?**

- យុទ្ធសាស្ត្រត្រូវបានបង្កើតឡើង ហើយសកម្មភាពពាក់ព័ន្ធត្រូវបានដាក់បញ្ចូលទៅក្នុងការធ្វើផែនការប្រចាំឆ្នាំ
- ភស្តុតាងក្នុងការកាត់បន្ថយជានជើងអវិជ្ជមានរបស់សាលា អនុលោមតាមគោលដៅដែលបានកំណត់
- ការផ្តួចផ្តើមគំនិត EAC ត្រូវបានបន្សីជាមួយគ្រប់ផ្នែកទាំងអស់ ហើយគឺជាផ្នែកមួយនៃវប្បធម៌ប្រចាំថ្ងៃ និងការសិក្សារៀនសូត្រទាំងអស់

**សកម្មភាពជាសក្ដានុពល ៣.១.i**

- បង្កើតមុខតំណែងទទួលខុសត្រូវ ក្នុងការអភិវឌ្ឍ និងមើលខុសត្រូវលើគោលវិធី ក្នុងសាលារៀនទាំងមូល។

**សកម្មភាពជាសក្ដានុពល ៣.១.ii**

- អនុវត្តសកម្មភាព និងការផ្តួចផ្តើមគំនិតដែលចូលរួមចំណែកជាវិជ្ជមានទៅក្នុងគោលដៅផ្នែកបរិស្ថានរបស់សាលាអន្តរជាតិភ្នំពេញ។

| |
|---|
| **សកម្មភាពជាសក្តានុពល ៣.២.iii**<br>- បង្កើតរចនាសម្ព័ន្ធគណនេយ្យភាពសម្រាប់ទាំងអស់គ្នា។ |
| **សកម្មភាពជាសក្តានុពល ៣.១.iv**<br>- ការផ្តួចផ្តើមគំនិតរបស់គណៈកម្មាធិការសកម្មភាពបរិស្ថានត្រូវបានពង្រីក និងដាក់បញ្ចូលនៅទូទាំងសាលារៀនទាំងមូល។ |
| **សកម្មភាពជាសក្តានុពល ៣.១.v**<br>- ប្រាស័យទាក់ទងអំពីការផ្តួចផ្តើមគំនិតឱ្យបានច្បាស់លាស់នៅក្នុងសាលារៀនទាំងមូល ក្នុងលក្ខណៈមួយដែលនឹងបន្តលើកកម្ពស់គុណតម្លៃ និងនិយាមផ្នែកបរិស្ថានរបស់សាលាអន្តជាតិភ្នំពេញ។ |
| **សកម្មភាពជាសក្តានុពល ៣.១.vi**<br>- ចាត់តាំងឱ្យមានធនធានសមស្របនៅក្នុងដំណើរការធ្វើថវិកាប្រចាំឆ្នាំ។ |
| **សកម្មភាពជាសក្តានុពល ៣.១.vii**<br>- ព្យាយាមបង្កើនការចូលរួមនៅក្នុងកម្មវិធីរថយន្តក្រុងសាលារៀន។ |
| **គោលបំណងយុទ្ធសាស្ត្រ ២**<br>ភាពជាដៃគូ និងសកម្មភាពនានា ត្រូវបានដាក់ឱ្យមាន ជាមួយស្ថាប័នទាំងឡាយណា ដែលមានគោលវិធី និងទស្សនវិជ្ជាផ្នែកបរិស្ថានប្រហាក់ប្រហែលគ្នា ហើយការយកចិត្តទុកដាក់ចំពោះបរិស្ថានត្រូវបានដាក់បញ្ចូលក្នុងការផ្សព្វផ្សាយ និងការធ្វើទីផ្សាររបស់សាលាអន្តរជាតិភ្នំពេញ<br><br>**តើយើងអាចដឹងដោយរបៀបណា?**<br>- ការប្រាស្រ័យទាក់ទងដើម្បីធ្វើទីផ្សារ និងទទួលសិស្សចូលរៀនរបស់សាលាអន្តរជាតិភ្នំពេញ រួមមានសារច្បាស់លាស់អំពីបរិស្ថាន<br>- សាលាអន្តរជាតិភ្នំពេញរក្សាចំណងទាក់ទង និងកិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងសហប្រតិបត្តិការដែលមានស្រាប់ជាមួយស្ថាប័នទាំងឡាយដែលមានទស្សនវិជ្ជា និងគោលវិធីប្រហាក់ប្រហែលគ្នាក្នុងការយកចិត្តទុកដាក់ចំពោះបរិស្ថាន និងការផ្តួចផ្តើមគំនិតដែលពាក់ព័ន្ធ ហើយអភិវឌ្ឍគោលវិធីថ្មីៗនៅពេលណាដែលមានឱកាសសមស្រប។ |
| **សកម្មភាពជាសក្តានុពល I:**<br>- អភិវឌ្ឍ និងអនុវត្តការផ្តួចផ្តើមគំនិតនានា សម្រាប់ការយកចិត្តទុកដាក់ចំពោះបរិស្ថាន នៅក្នុងសហគមន៍ |
| **សកម្មភាពជាសក្តានុពល II:** |

- អភិវឌ្ឍ និងប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យការយកចិត្តទុកដាក់ផ្នែកបរិស្ថាន និងការប្រាស័យទាក់ទងសម្រាប់អ្នកលក់ និងអ្នកផ្គត់ផ្គង់ពីខាងក្រៅ។

## ៤. សសរស្តម្ភសុខុមាលភាព

**គោលដៅជាទីប្រាថ្នា**
វប្បធម៌សាលារៀនមានការប្រកាន់ខ្ជាប់ គាំទ្រ បង្ហាញសកម្មភាព និងបង្កើតឱ្យមានផលប៉ះពាល់ជាវិជ្ជមានចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃសុខុមាលភាពសម្រាប់សិស្ស បុគ្គលិកសិក្សា បុគ្គលិក និងសហគមន៍។

**គោលបំណងយុទ្ធសាស្ត្រ ៤.១**
សាលាអន្តរជាតិភ្នំពេញ ប្រកាន់ខ្ជាប់តាមការអនុវត្តប្រសើរបំផុតដែលមានសព្វថ្ងៃ ក្នុងការលើកកម្ពស់សុខភាព និងសុខុមាលភាព។

**តើយើងអាចដឹងដោយរបៀបណា?**
- លទ្ធផលការសិក្សាអង្កេត (លើស ៩០ ភាគរយ = ការអបអរ)

**សកម្មភាពជាសក្តានុពល ៤.១.i**
- អភិវឌ្ឍកម្មវិធីសិក្សាផ្នែកសង្គម និងផ្លូវចិត្ត ដែលមានលក្ខណៈសម្របសម្រួល និងបន្សីគ្នា។

**សកម្មភាពជាសក្តានុពល ៤.១.ii**
- ពិចារណាអភិវឌ្ឍឱ្យមានគោលវិធី "សាលារៀនរុងរឿង"

**គោលបំណងយុទ្ធសាស្ត្រ ៤.២**
វប្បធម៌របស់សាលាអន្តរជាតិភ្នំពេញ មានការយកចិត្តទុកដាក់ និងមានលក្ខណៈស្វាគមន៍ចំពោះមនុស្សគ្រប់រូប។

**តើយើងអាចដឹងដោយរបៀបណា?**
- លទ្ធផលការសិក្សាអង្កេត (លើស ៩០ ភាគរយ = ការអបអរ)

**សកម្មភាពជាសក្តានុពល ៤.២.i**
- ពិនិត្យឡើងវិញ និងពង្រឹងកម្មវិធីការផ្លាស់ប្រែសម្រាប់សិស្ស គ្រួសារ បុគ្គលិកសិក្សា និងបុគ្គលិក។

**សកម្មភាពជាសក្ដានុពល ៤.២.ii**

- ធានាឱ្យបានថា សាលាអភិវឌ្ឍឱ្យមាននិយាមវប្បធម៌សមស្រប ដែលគាំទ្រឱ្យមានវប្បធម៌ការយកចិត្តទុកដាក់ និងស្វាគមន៍សម្រាប់ទាំងអស់គ្នា។

**គោលបំណងយុទ្ធសាស្ត្រ ៤.៣**

ប្រព័ន្ធ និងសកម្មភាពដើម្បីធានាសុខភាព សុវត្ថិភាព និងសន្តិសុខសម្រាប់សិស្ស បុគ្គលិកសិក្សា បុគ្គលិក និងភ្ញៀវទាំងអស់របស់សាលាអន្តរជាតិភ្នំពេញ ហើយត្រូវបានពិនិត្យតាមដាន និងធ្វើបច្ចុប្បន្នភាពយ៉ាងស៊ីសង្វាក់។

**តើយើងអាចដឹងដោយរបៀបណា?**

- នីតិវិធីក្នុងការរាយការណ៍ជាប្រចាំ លើករណីកើតហេតុបញ្ហាគួរជាទីកង្វល់ និងរបៀបដែលបញ្ហាទាំងនោះត្រូវបានដោះស្រាយ

**សកម្មភាពជាសក្ដានុពលៈ ៤.៣.i**

- ការពិនិត្យឡើងវិញ និងកែលម្អជាប្រចាំលើនីតិវិធីសុខភាព សុវត្ថិភាព និងសន្តិសុខ

**គោលបំណងយុទ្ធសាស្ត្រ ៤.៤**

បរិស្ថានរូបវន្តរបស់សាលា មានលក្ខណៈស៊ីសង្វាក់ជាមួយវប្បធម៌សាលារៀន និងគាំទ្រដល់ការសិក្សារៀនសូត្រ និងសុខុមាលភាព។

**តើយើងអាចដឹងដោយរបៀបណា?**

- មណ្ឌលសិក្សារូបវន្តត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការសិក្សារៀនសូត្រ ហើយត្រូវបានថែទាំ និងកែលម្អជាប្រចាំដើម្បីបំពេញមុខងារតាមគោលបំណង

**សកម្មភាពជាសក្ដានុពល ៤.៤.i**

- ធានាឱ្យបានថា សុខុមាលភាពគឺជាការពិចារណាចម្បង នៅក្នុងការធ្វើផែនការ និងការអភិវឌ្ឍមជ្ឈមណ្ឌលអប់រំក្រៅបន្ទប់សិក្សា

**សកម្មភាពជាសក្ដានុពល ៤.៤.ii**

- ពិនិត្យឡើងវិញលើបរិក្ខារនាពេលបច្ចុប្បន្ន និងដាក់ឱ្យមានការពង្រឹងបរិក្ខារដែលនឹងជួយសម្របសម្រួលដល់សុខុមាលភាព "សមស្របតាមគោលបំណង" សម្រាប់ការសិក្សារៀនសូត្រ។